VisionFund

វីសិនហ្វាន់ គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលមានបណ្តាញប្រតិបត្តិការក្នុង ៣៥ប្រទេស ជុំវិញពិភពលោក។ វីសិនហ្វាន់ មានបេសកកម្មសង្គមដើម្បីលើកស្ទួយជីវិតកុមារឲ្យកាន់តែប្រសើរឡើង តាមរយៈការផ្តល់ប្រាក់កម្ចីខ្នាតតូច ព្រមទាំងសេវាហិរញ្ញវត្ថុផ្សេងៗដល់គ្រួសាររបស់ពួកគេ។ កិច្ចការរបស់យើង គឺផ្តល់អំណាចដល់ អតិថិជន ឲ្យទទួលបានជោគជ័យក្នុងអាជីវកម្មរបស់គេ ដែលនឹងផ្តល់លទ្ធភាពដល់កូនៗ របស់ពួកគេ ធំធាត់ប្រកបដោយសុខភាពល្អ និងទទួលបានការសិក្សាអប់រំប្រសើរជាងមុន។ ក្នុងភាពជាដៃគូជាមួយអង្គការទស្សនៈពិភពលោក យើងប្តេជ្ញាធ្វើឲ្យមានបំលាស់ប្រែយូរ អង្វែង ដែលនឹងផ្តល់សក្តានុពលរុងរឿងឲ្យមនុស្សជំនាន់ក្រោយៗទៀត។

# ដំណឹងជ្រើសរើសបុគ្គលិក

| | |
|---|---|
| តំណែង : | មន្រ្តីបម្រើសេវាអតិថិជន (ឬ មន្រ្តីឥណទាន) (Client Services Officer) |
| ប្រាក់ខែ: | ២៥៥ ដុល្លារ (ប្រាក់ខែបន្ទាប់ពីចប់ការសាកល្បងការងារនិងប្រាក់សុខភាព) |
| សម្រាប់សាខា : | សាខាខេត្តកណ្តាល ភ្នំពេញ ព្រះវិហារ ក្រចេះ ពោធិ៍សាត់ រតនៈគិរី ស្ទឹងត្រែង កំពង់សោម ត្បូងឃ្មុំ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម សៀមរាប |

**វីសិនហ្វាន់** ត្រូវការជ្រើសរើសបុគ្គលិកចំនួន **៣០នាក់** សម្រាប់តំណែង **មន្រ្តីបម្រើសេវាអតិថិជន (មន្រ្តីឥណទាន) (Client Services Officer)**។ បេក្ខជន បេក្ខនារី ដែលបានជាប់នឹងត្រូវធ្វើការនៅតាមសាខាស្រុកប្រតិបត្តិការនៃបណ្តាសាខាខេត្ត ដែលបានបញ្ជាក់ខាងលើ។ បេក្ខជនដែលជាប់ នឹងមានភារកិច្ចក្នុងការបម្រើ សេវាហិរញ្ញវត្ថុ (ប្រាក់កម្ចី ប្រាក់បញ្ញើរ) និង សេវាមិនមែនហិរញ្ញវត្ថុរបស់ **វីសិនហ្វាន់** ដល់អតិថិជន។

## ការទទួលខុសត្រូវសំខាន់ៗ:

- ស្វែងរកអតិថិជនគោលដៅនៅក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន
- ទំនាក់ទំនង និង ផ្សព្វផ្សាយផលិតផល ទៅអតិថិជន អាជ្ញាធរមូលដ្ឋាន និង ភាគីពាក់ព័ន្ធ
- ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បីប្រមូលព័ត៌មាន និង ដោះស្រាយបញ្ហា
- ធ្វើការណាត់ជួប និង ពន្យល់អតិថិជនពីលក្ខខណ្ឌដែលអាចទទួលបានប្រាក់កម្ចី
- បញ្ចេញប្រាក់កម្ចី និង ប្រមូលប្រាក់បង់សងត្រលប់ទាន់ពេលវេលា
- តាមដានការប្រើប្រាស់ប្រាក់កម្ចីរបស់អតិថិជន បន្ទាប់ពីទទួលប្រាក់កម្ចី
- សហការល្អជាមួយមន្រ្តីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន
- ធ្វើរបាយការណ៍ អំពីសកម្មភាពសម្រេចបាន និង បញ្ហាប្រឈមទៅកាន់ប្រធាន។

## លក្ខណៈសម្បត្តិ:

- ស្គាល់ និង សម្របតាម បេសកកម្ម គោលដៅ តម្លៃជាមូលដ្ឋាន និង រាល់និតិវិធីរបស់ **វីសិនហ្វាន់**
- កំពុងសិក្សា ឬ គ្រោងនឹងបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ លើជំនាញ ផ្នែកធនាគារ និងហរិញ្ញវត្ថុ គ្រប់គ្រង សេដ្ឋកិច្ច ឬជំនាញ ដែលពាក់ព័ន្ធផ្សេងទៀត
- មានជំនាញក្នុងការប្រាស្រ័យទាក់ទង ការផ្សព្វផ្សាយ ការវិភាគ និង ការគណនា
- អាចចេះ ស្តាប់ សរសេរ ភាសាអង់គ្លេស និង ចេះប្រើប្រាស់កម្មវិធីកុំព្យូទ័រខ្លះៗ កាន់តែប្រសើរ
- មានភាពស្មោះត្រង់ និង ទំនួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន
- មានភាពរួសរាយរាក់ទាក់ និង មានការប្តេជ្ញាចិត្តធ្វើការជាមួយប្រជាជនក្រីក្រនៅក្នុងសហគមន៍
- មានភាពច្បាស់លាស់ និង ម៉ត់ចត់ក្នុងការបំពេញភារកិច្ច
- ស្វែងយល់យ៉ាងច្បាស់អំពីស្ថានភាពក្នុងសហគមន៍ដែលខ្លួនធ្វើការ

- មានការគោរព និង ឥតលំអៀងក្នុងពេលបំពេញភារកិច្ចជាមួយគ្រប់អតិថិជន
- មានឆន្ទៈក្នុងការចែករំលែក សហការណ៍ និង បំពេញការងារជាក្រុម
- អាចធ្វើដំណើរដោយម៉ូតូតាមតំបន់ដាច់ស្រយាលជាប្រចាំ **និងត្រូវមានប័ណ្ណបើកបរម៉ូតូ ឬរថយន្ត**
- ត្រូវមានម៉ូតូផ្ទាល់ខ្លួន ដែលម៉ូតូនោះអាចប្រើប្រាស់សម្រាប់ផ្លូវឆ្ងាយបាន
- មានទីលំនៅក្នុងតំបន់ ឬ ខេត្តដែលប្រតិបត្តិការកាន់តែប្រសើរ។

**<u>កញ្ចប់សំណងទូទាត់:</u>**

វីសិនហ្វាន់ ផ្តល់ជូនកញ្ចប់សំណងទូទាត់ ដែលមានភាពប្រកួតប្រជែងដោយយោងទៅតាមកម្រិតការសិក្សា និង បទពិសោធន៍ការងាររបស់បេក្ខជន។ វីសិនហ្វាន់ ផ្តល់នូវការអភិវឌ្ឍន៍ខ្លួនតាមរយៈ ការបណ្តុះបណ្តាល និង បង្កើនសមត្ថភាពជាបន្តបន្ទាប់ ឱកាសរីកចម្រើនឡើងក្នុងអាជីពការងារ ព្រមជាមួយនឹងកញ្ចប់អត្ថប្រយោជន៍ជាច្រើនដូចជា: ការតម្លើងប្រាក់ខែប្រចាំឆ្នាំ ប្រាក់ខែទី១៣ ប្រាក់លើកទឹកចិត្តជាក្រុមប្រចាំឆ្នាំ ប្រាក់បំណាច់ឬប្រាក់បង្គរសន្សំទុក ពេលលាឈប់ពីការងារ (ឬ ប្រាក់សោធន៍និវត្តន៍) ប្រាក់កម្ចីសម្រាប់បុគ្គលិក ប្រាក់ឧបត្ថម្ភសុខភាព និង ការឧបត្ថម្ភផ្សេងៗទៀត ការធានារ៉ាប់រងគ្រោះថ្នាក់ផ្ទាល់ខ្លួនពេញ២៤ម៉ោង ការធានារ៉ាប់រងសុខភាព ការធានារ៉ាប់រងជីវិត និងមានកម្មវិធីលើកទឹកចិត្តដល់បុគ្គលិកផ្សេងៗទៀតដូចជា ការលើកទឹកចិត្តបុគ្គលិកបម្រើការងារយូរឆ្នាំ ឱកាសចូលរួមកម្មវិធីដំណើរកំសាន្តប្រចាំឆ្នាំ និង កម្មវិធីសម្រាកលំហែរជាក្រុមជាដើម។

**បេក្ខនារីត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យបម្រើការងារជាមន្ត្រីឥណទាន**

បេក្ខជន បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមបំពេញពាក្យសុំចូលបម្រើការងាររបស់ **វីសិនហ្វាន់** ជាកំហិត និង ប្រវត្តិរូបសង្ខេប ផ្ញើមក តាមរយៈអ៊ីម៉ែល: vfc_recruitment@wvi.org ឬផ្ញើមកកាន់ការិយាល័យ **វីសិនហ្វាន់** គ្រប់សាខាទាំងអស់ដែលនៅជិតលោក-អ្នក។

**ផុតកំណត់ឈប់ទទួលពាក្យ ថ្ងៃទី០៨ ខែឧសភា ២០១៧ វេលាម៉ោង ៥:០០ល្ងាច**

**អាសយដ្ឋានការិយាល័យកណ្តាល:** អាគារលេខ ៣៩៨ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: 089 333 767 | Web site : www.visionfund.com.kh/careers

**ការិយាល័យប្រចាំតំបន់ភ្នំពេញ:** ១៥២B២ ផ្លូវលេខ៥១៦ ភូមិទី១៣ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
**ការិយាល័យប្រចាំតំបន់ខេត្តកណ្តាល:** ផ្ទះលេខ២៤០ ផ្លូវជាតិលេខ២ ភូមិក្រពើហា សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល
**ការិយាល័យប្រចាំតំបន់ខេត្តព្រះវិហារ:** ភូមិថ្មី សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
**ការិយាល័យប្រចាំតំបន់ខេត្តក្រចេះ:** ភូមិអូរឫស្សី សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
**ការិយាល័យប្រចាំតំបន់ខេត្តពោធិ៍សាត់:** ផ្ទះលេខ៤៧៥ ផ្លូវជាតិលេខ៥ ភូមិក្រាំងពព្លាក់ សង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
**ការិយាល័យប្រចាំតំបន់ខេត្តរតនៈគិរី:** ភូមិជ័យជំនះ សង្កាត់ ឡាបានសៀក ក្រុង បានលុង ខេត្ត រតនៈគិរី
**ការិយាល័យសាខាស្ថិតក្នុងខេត្តស្ទឹងត្រែង:** ភូមិ ស្ពានថ្ម ឃុំ ស្ទឹងត្រែង ស្រុក ស្ទឹងត្រែង ខេត្ត ស្ទឹងត្រែង
**ការិយាល័យប្រចាំតំបន់ខេត្តកំពង់សោម** : ភូមិ ៣ សង្កាត់ លេខ២ ខណ្ឌមិត្តភាព ក្រុងកំពង់សោម
**ការិយាល័យប្រចាំតំបន់ខេត្តត្បូងឃ្មុំ:** ផ្លូវជាតិលេខ៧ ភូមិ ជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ
**ការិយាល័យប្រចាំតំបន់ខេត្តបាត់ដំបង:** ផ្ទះលេខ៩៩ ផ្លូវជាតិលេខ៣ ភូមិ២០ ឧសភា សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
**ការិយាល័យប្រចាំតំបន់ខេត្តប៉ៃលិន:** អូរតាពុកលើ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
**ការិយាល័យប្រចាំតំបន់ខេត្តបន្ទាយមានជ័យ:** ផ្លូវជាតិលេខ៦ ភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
**ការិយាល័យប្រចាំតំបន់ខេត្តកំពង់ចាម:** ភូមិបឹងស្នាយ សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម
**ការិយាល័យប្រចាំតំបន់ខេត្តសៀមរាប:** ផ្ទះលេខ៧៦ ផ្លូវជាតិលេខ៦ ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។